ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៨៨/១០-យីងខា**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន យីងខា (ខេមបូឌា) និតធីង**

អាសយដ្ឋាន : ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៨៥១៥០៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជក : **គ្មាន**

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ : ~ **សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ**

~ **សហជីពសម្លេងយុវជនខ្មែរ នៃរោងចក្រ យីងខា**

អាសយដ្ឋាន : ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៧១៣ ០៦៥ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **គ្មាន**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤

No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◆ Tel/Fax: 855-23 881 824

E-mail: secretariat@arbitrationcouncil.org ◆ Website: www.arbitrationcouncil.org

# បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនទទួលថ្នាក់ដឹកនាំសហជីពសម្លេងយុវជនខ្មែរ ប្រចាំក្រុមហ៊ុនឈ្មោះ សៅ ពិសាល ឱ្យចូលធ្វើការជាធម្មតាវិញ (ចំពោះចំណុចទី១ នេះ អ្នកផ្សះផ្សាយល់ឃើញថា ជាវិវាទបុគ្គល) ។

២- សូមឱ្យក្រុមហ៊ុនបើកប្រាក់ជូសការឈប់សម្រាកប្រចាំឆ្នាំឱ្យបានពីរដងក្នុងមួយឆ្នាំ គឺបុណ្យភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំ ។

៣- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតឱ្យបានរៀងរាល់ថ្ងៃទី០៧ នៃខែបន្ទាប់ ។

៤- នៅពេលកម្មករកម្មការិនីសុំច្បាប់ឈឺ ហើយមានសំបុត្រពេទ្យ សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់ ។

៥- នៅពេលក្រុមហ៊ុនដាក់ PO ថ្មីឱ្យកម្មករធ្វើ សុំឱ្យក្រុមហ៊ុនចេញតម្លៃឡូតិ៍ឱ្យកម្មករដឹងមុន ០៧ ថ្ងៃ ។

៦- សូមឱ្យក្រុមហ៊ុនរៀបចំពេទ្យប្រចាំការគ្រប់ពេលម៉ោងកម្មករធ្វើការ ។

៧- សុំឱ្យក្រុមហ៊ុនរៀបចំទឹកស្អាតជូនកម្មករឱ្យបានហូបគ្រប់គ្រាន់ និងមានអនាម័យ ។

៨- សុំឱ្យក្រុមហ៊ុនរៀបចំសម្ភារៈជូនកម្មករ កម្មការិនីឱ្យបានគ្រប់គ្រាន់ ។

៩- នៅពេលកម្មករ កម្មការិនីលាលែងពីការងារ សូមឱ្យក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ ។

១០- សុំឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូនឱ្យបានត្រឹមត្រូវតាមស្តង់ដារក្រសួង ។

១១- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះចេញមុនម៉ោង ១៥ នាទី មួយវគ្គ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់ ។

១២- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យផ្ទៃពោះមួយខែម្តង ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់ ។

១៣- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល ៥០ ភាគរយ និងប្រាក់បន្ទាប់បន្សំ ជូនកម្មការិនីឱ្យបានមុនដាក់ច្បាប់សំរាលកូន (បញ្ជាក់ចំនួន ៣ ខែ ) ។

១៤- សុំឱ្យក្រុមហ៊ុនធ្វើការណែនាំបុគ្គលិកខ្មែរ ឬគ្រូបង្ហាត់ជនជាតិចិននៅផ្នែកនីមួយៗ ឱ្យចេះប្រើសំដីសមរម្យមកលើកម្មករកម្មការិនី ។

១៥- នៅពេលកម្មករ កម្មការិនីបាត់បង់សំភារៈ សុំឱ្យក្រុមហ៊ុនទទួលខុសត្រូវ ។

១៦- សុំឱ្យក្រុមហ៊ុនដាក់អំពូលភ្លើងតាមអគារផលិតកម្មឱ្យបានគ្រប់គ្រាន់ ។

១៧- នៅពេលកម្មករ កម្មការិនីមកធ្វើការយឺត ១៥ នាទី ដោយមូលហេតុម៉ូតូ ឬរថយន្តខូច សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់ ។

THE ARBITRATION COUNCIL

១៨- នៅពេលកម្មករ កម្មការិនីសុំច្បាប់មានធុរៈ សុំឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ទៀងទាត់តាមមធ្យមភាគ ឈប់មួយថ្ងៃកាត់ប្រាក់រង្វាន់មួយថ្ងៃ ។

១៩- សុំឱ្យក្រុមហ៊ុនជ្រើសរើសកម្មករផ្នែកអនាម័យបន្ថែមទៀត ។

២០- សុំឱ្យក្រុមហ៊ុនកុំប្រើកម្មករជំនាញធ្វើការផ្នែកអនាម័យ ។

២១- សុំឱ្យក្រុមហ៊ុនទិញអាវភ្លៀងជូនកម្មករម្នាក់ចំនួន ០២ សម្រាប់ក្នុងរដូវភ្លៀង ។

២២- សុំឱ្យក្រុមហ៊ុនសង់បន្ទប់ទឹកបន្ថែម និងដាក់សំភារៈប្រើប្រាស់ផង ។

២៣- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករ កម្មការិនីឈប់សម្រាកពិសេស ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ។

២៤- នៅពេលកម្មករ កម្មការិនីស្ម័គ្រធ្វើការថែមម៉ោងថ្ងៃបុណ្យ និងថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលគុណបី និងផ្តល់បាយមួយពេល ឬជំនួសដោយប្រាក់ ៤០០០ រៀល ។

២៥- សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលរបស់កម្មករ កម្មការិនីជាសមាជិកសហជីពសម្លេងយុវជនខ្មែរចំនួន ១០០០ រៀលរៀងរាល់ខែ ដើម្បីបង់ភាគទានសហជីព ។

២៦- សុំឱ្យក្រុមហ៊ុនដកប្រធានរដ្ឋបាលឈ្មោះ ចៅ ផេង ចេញពីក្រុមហ៊ុនជាបន្ទាន់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤៨៧/១០ កប/កណ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១០ (វេលាម៉ោង ១៤ : ០០ នាទី រសៀល) ។

THE ARBITRATION COUNCIL

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលបណ្តឹងរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១០ ទាមទារឱ្យកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ និងផ្សះផ្សានៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ២៦ ចំណុច លើការទាមទារចំនួន ២៦ ចំណុច។ ចំណុចមិនសះជាចំនួន ២៦ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ តាមរបាយការណ៍ស្តីពីវិវាទការងាររួមមិនសះជាលេខ ៤៨៧/១០ ក.ប/កណ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន២៦ចំណុចនេះ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០ (វេលាម៉ោង ១៤:០០ នាទីរសៀល)។ ប៉ុន្តែ ភាគីកម្មករនិយោជិត និងនិយោជកមិនបានចូលរួមសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយក៏មិនបានបញ្ជាក់អំពីមូលហេតុច្បាស់លាស់នៃការមិនបានមកចូលរួមសវនាការនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោមៈ

## **ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យីងឡា (ខេមបូឌា) លេខ ៤៨៧/១០ កប/កណ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យីងឡា (ខេមបូឌា) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៤៤៥ កប/អក/វក/លកអ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០។

THE ARBITRATION COUNCIL

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៤៤៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០។

**ការរកឃើញអង្គហេតុ:**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុទាក់ទងនឹងការទាមទារទាំងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិត និង និយោជកអវត្តមាននៅថ្ងៃសវនាការ ដោយមិនបានផ្តល់មូលហេតុណាមួយឡើយ។

**ហេតុផលក្នុងការធ្វើសេចក្តីសម្រេច:**

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ *" ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ "* ។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *" ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "* ។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់លេខ ៣០/០៥-មូរៀ, លេខ ១៦/០៧- ឡូទូសតី, លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន, លេខ ០៩/០៩-នីមបឹស ថិចថាយ៍ លេខ ០១/១០-ខិននីតិច, លេខ ៣០/១០-ក្លូប៉ល អាប៉ារែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ មុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុសម្រាប់ការមិនបង្ហាញខ្លួន។

ដូច្នេះ នៅក្នុងសំណុំរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរឬទេ?

THE ARBITRATION COUNCIL

**លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងករណីអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល។ ក្នុងករណីនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការ (ជាលាយលក្ខណ៍អក្សរ) ទៅកាន់ភាគីនិយោជក លេខ ៤៤៥ លកអ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០ និងទៅកាន់ភាគីកម្មករនិយោជិត លេខ ៤៤៦ លកអ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងតាមនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីទាំងពីរអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃថ្ងៃសវនាការ តាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរត្រូវបានជូនដំណឹងដោយត្រឹមត្រូវ ពីសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២: ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

បន្ថែមពីនេះទៀត ប្រការ ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិត និងភាគីនិយោជកមិនបានមកចូលរួមសវនាការ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង (ដូចជាខាងសហព័ន្ធសហជីព ឬមេធាវី) ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣: ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ក្នុងករណីភាគី

THE ARBITRATION COUNCIL

បានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិត និងភាគីនិយោជកអវត្តមាន និងមិនបានផ្តល់មូលហេតុត្រឹមត្រូវអ្វីទាំងអស់ដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីការមិនចូលរួមសវនាការនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ៨៨/១០-ឃីងឌា (ខេមបូឌា) នីតធីង នេះ ដោយភាគីកម្មករនិយោជិត និងភាគីនិយោជកមិនមានវត្តមាននៅពេលសវនាការ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង និងអង្គច្បាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ:

## សម្រេច និង បង្គាប់

បិទសំណុំរឿងលេខ ៨៨/១០-ឃីងឌា (ខេមបូឌា) នីតធីង ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ុង សុទ្ធី**

ហត្ថលេខា: ---------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ---------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ---------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL